# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៩៧ ព.ណ.ឯ.ក.ពបប

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌតម្រូវនៃការដាក់ស្លាកសញ្ញាសម្រាប់ផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៧ ១២ ១៣ ១៤ ឧបសម្ព័ន្ធ២ ៣ និង៤នៃអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី
- បានឃើញប្រកាសលេខ១៨៣ MOC/SM 2006 ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីសារធាតុគីមីហាមប្រើលើផលិតផលម្ហូបអាហារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់ពីលក្ខខណ្ឌតម្រូវ សម្រាប់ការដាក់ស្លាកសញ្ញាលើផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន ដែលចែកចាយលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងការពារសុខុមាលភាព និងផលប្រយោជន៍អ្នកប្រើប្រាស់។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន ដែលចែកចាយលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗប្រើក្នុងប្រកាសនេះមានអត្ថន័យដូចតទៅៈ

១. **ផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន** សំដៅដល់សារធាតុគីមី ឬផលិតផលគីមីដែលមានលក្ខណៈជាផលិតផលសម្រេច ដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព ហើយត្រូវបានប្រើប្រាស់ជាសារធាតុជំនួយសម្រាប់គោលបំណងផ្សេងៗនៃជីវភាពរស់នៅធម្មតាមានដូចជា ការប្រើប្រាស់នៅតាមផ្ទះ រោងជាង ប្រើប្រាស់ក្នុងសួន ឬកន្លែងផ្តល់សេវាសាធារណៈផ្សេងៗទៀត ផលិតផលទាំងនោះត្រូវបានកំណត់ចំណាត់ថ្នាក់ ដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ។

២. **ព័ត៌មានសុវត្ថិភាពបន្ថែម** សំដៅដល់ព័ត៌មានដែលពិពណ៌នាអំពីកម្រិតគ្រោះថ្នាក់ទៅតាមប្រភេទនិងថ្នាក់របស់វា។

៣. **សារព្រមាន** សំដៅដល់ការព្រមានដែលបិទភ្ជាប់ពាក្យ "គ្រោះថ្នាក់" ឬ "ប្រយ័ត្ន" លើស្លាកសញ្ញាផលិតផលគីមីនោះទៅតាមកម្រិតគ្រោះថ្នាក់របស់វា។

៤. **រូបសញ្ញា** សំដៅដល់រូបសញ្ញាបង្ហាញពីប្រភេទគ្រោះថ្នាក់លើស្លាកសញ្ញាផលិតផលគីមីនោះ ដើម្បីជូនដំណឹងអំពីគ្រោះថ្នាក់នៃផលិតផលគីមីទាំងនោះ ដោយអនុលោមតាមតារាង៤បសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១។

៥. **ធុរកិច្ច** សំដៅដល់សកម្មភាពដែលៈ

- ទំនិញ ឬសេវា ត្រូវបានផ្តល់ ឬទទួល ឬ
- បានធ្វើឡើងតាមវិធីដែលមានការរៀបចំ និងមានភាពច្បាស់លាស់ ឬ
- បុគ្គលធ្វើសកម្មភាពនោះមានគោលបំណងរកប្រាក់ចំណេញទោះបីសកម្មភាពដែលបានធ្វើដោយបុគ្គលនោះជាសកម្មភាពចម្បង បន្ទាប់បន្សំ ឬមិនធ្វើជាប្រចាំក៏ដោយ។

៦. **បុគ្គលធ្វើធុរកិច្ចផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន** សំដៅដល់បុគ្គលផ្គត់ផ្គង់ផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន ក្នុងនោះមានការលក់ដុំ ការលក់រាយ ការផ្តល់ជាអំណោយ ឬការឱ្យប្រើសាកល្បង។

៧. **ការប្រមូលត្រឡប់មកវិញ** សំដៅដល់ការអនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងការប្រមូលត្រឡប់មកវិញនូវផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋានដែលគ្មានគុណភាព សុវត្ថិភាព ឬដែលមិនអនុលោមតាមបទដ្ឋានព័ត៌មាន ដែលបានចែកចាយ ឬចរាចរលើទីផ្សារ។

៨. **ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់សកម្មភាពទិញលក់ ជួល ផ្លាស់ប្តូរទំនិញ ឬសេវាដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្មនិងរដ្ឋប្បវេណី ព្រមទាំងសកម្មភាពនិងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក។

៩. **សារធាតុរំលាយ** សំដៅដល់សារធាតុទាំងឡាយណា ដែលមានសមត្ថភាពរំលាយអង្គធាតុ ឬសមាសធាតុមួយផ្សេងទៀតឱ្យលាយក្លាយជាល្បាយស្មើសាច់មានជាអាទិ៍ តូលុយអែន(Toluene) អាសេតូន (Acetone) អេទីលអាសេតាត(Ethyl acetate) អេតាណុល(Ethanol) ម៉េតាណុល (Methanol) អ៊ីហ្សូប្រូពីលអាល់កុល(Isopropyl Alcohol) និងសារធាតុផ្សេងៗទៀត។

១០. **ការចែកចាយ** សំដៅដល់សកម្មភាពផ្គត់ផ្គង់ផលិតផលទំនិញលើទីផ្សារ ក្នុងនោះមាន ការលក់ដុំ ការលក់រាយ ការផ្តល់ជាអំណោយ ឬឱ្យប្រើសាកល្បង។

**ប្រការ៤.-**

បុគ្គលធ្វើធុរកិច្ចផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន ត្រូវទទួលខុសត្រូវលើផលិតផលរបស់ខ្លួន ដោយធានាថាផលិតផលទាំងនោះមានគុណភាពនិងសុវត្ថិភាព និងបានដាក់ស្លាកសញ្ញាត្រឹមត្រូវអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋានទាំងអស់ ដែលចែកចាយលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតនាំចូល ផលិត និងចែកចាយពីក្រសួង ឬស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

**ប្រការ៥.-**

ផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋានទាំងអស់ ត្រូវដាក់តាំងលក់នៅកន្លែងសមស្រប មានសុវត្ថិភាព និងដាច់ដោយឡែកពីផលិតផលម្ហូបអាហារ។

**ប្រការ៦.-**

រាល់ការដាក់ស្លាកសញ្ញាផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន មិនត្រូវបង្ហាញឬបរិយាយក្នុងលក្ខណៈមិនពិត បំភាន់ ឬបោកបញ្ឆោតអ្នកប្រើប្រាស់ឡើយ។

ផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋានទាំងអស់ ដែលចែកចាយលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានបទដ្ឋានព័ត៌មានអប្បបរមាជាភាសាខ្មែរ ដែលអាចបិទភ្ជាប់លើសម្បកវេចខ្ចប់-ឬបរិយាយបណ្ណដោយភ្ជាប់ជាមួយនឹងផលិតផលនោះ។ លក្ខខណ្ឌតម្រូវនៃបទដ្ឋានព័ត៌មានអប្បបរមាមានជាអាទិ៍៖

- ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនងរបស់អ្នកផលិត អ្នកនាំចូល អ្នកចែកចាយ ឬអ្នកទទួលខុសត្រូវ
- ឈ្មោះសម្គាល់ផលិតផល រួមមាន ឈ្មោះទូទៅ (Common Name) ពាណិជ្ជនាម (Trade Name) ឬឈ្មោះគីមី (Chemical Name)
- កាលបរិច្ឆេទផលិត កាលបរិច្ឆេទផុតកំណត់ប្រើប្រាស់ និងលេខកូដឬលេខបាច់/ឡូត៍ (Batch/Lot Number)
- សមាសធាតុផ្សំសកម្ម(Active Ingredient)(អាចជាភាសាបារាំង ឬអង់គ្លេស)
- មុខងារ ការប្រើប្រាស់ របៀបប្រើប្រាស់ និងការរក្សាទុកដាក់
- សារព្រមានចំពោះក្មេង
- ពាក្យគន្លឹះចង្អុលបង្ហាញពីគ្រោះថ្នាក់ (Signal Word) មានដូចជា ការព្រមានពីហានិភ័យ ឬគ្រោះថ្នាក់
- សេចក្តីរាយការណ៍បង្ហាញពីហានិភ័យ (Hazard Statement)
- សេចក្តីរាយការណ៍បង្ហាញពីការប្រុងប្រយ័ត្នជាមុន (Precautionary Statement)
- ព័ត៌មានបំពេញបន្ថែមផ្សេងទៀត (Supplementary Information)

- រូបសញ្ញា/និមិត្តសញ្ញាពីគ្រោះថ្នាក់(Pictograms and Graphic Symbols) ដូចមានក្នុងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក
- ការណែនាំពីវិធីសង្គ្រោះបន្ទាន់។

ក្នុងករណី ទំហំ រូបរាង ឬលក្ខណៈសម្បត្តិរបស់សម្បកវេចខ្ចប់ ឬស្លាកសញ្ញាវេចខ្ចប់មិនអាចមានទំហំគ្រប់គ្រាន់ សម្រាប់បរិយាយខ្លឹមសារដូចបានកំណត់តាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានព័ត៌មានខាងលើ បុគ្គលធ្វើធុរកិច្ចផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន អាចប្រើប្រាស់បរិយាយបណ្ណ ស្លាកបិទបន្ទះព័ត៌មានដាក់តាំងបង្ហាញសម្ភារៈរុំព័ទ្ធពីក្រៅ ឬមធ្យោបាយផ្សេងទៀតបាន។

ផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន ដែលចែកចាយលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជាអាចអនុញ្ញាតឱ្យប្រើឈ្មោះសម្គាល់ផលិតផលជាភាសាអង់គ្លេស ឬបារាំង និងត្រូវបកប្រែជាភាសាខ្មែរ ដូចជាឈ្មោះទូទៅ (Common Name) ពាណិជ្ជនាម ( Trade Name ) ឬឈ្មោះគីមី (Chemical Name)។

**ប្រការ៧.-**

រាល់សារធាតុគីមីដែលប្រើប្រាស់តាមគេហដ្ឋាន ត្រូវបានចាត់ថ្នាក់ជាក្រុមតាមគោលដៅប្រើប្រាស់ដូចខាងក្រោម៖

ក. សារធាតុលាងសម្អាតមានជាអាទិ៍៖

- សាប៊ូបោកគក់ (Laundry detergents)
- សារធាតុសម្រាប់សម្អាតទូទៅ
- សារធាតុធ្វើឱ្យស (Bleaching Agents)
- សាប៊ូលាងចាន (Dishwashing detergents)
- សាប៊ូលាងឡកម្ដៅ/ចង្ក្រានអាំងសាច់ (Oven cleaners)
- សាប៊ូសម្លាប់មេរោគ (Antibacterial cleaner)
- សាប៊ូសម្អាតបង្អួច/កញ្ចក់ (Window and glass cleaner)
- សាប៊ូលាងសម្អាតបង្គន់ (Toilet bowl cleaners)
- សារធាតុសម្អាតស្អិម (Mold and mildew removers)
- សារធាតុសម្អាតការ៉ូ និងបំពង់ទុយោបង្ហូរ (Drain cleaners)
- ថ្នាំក្លរសម្រាប់អាងហែលទឹក (Swimming pool chloride tablets)
- ថ្នាំកម្ចាត់ស្លែក្នុងអាងហែលទឹក (Algicides for the pool)
- សារធាតុសម្អាតព្រំ ពូកសាឡុង (Rug, carpet, upholstery cleaners)
- សារធាតុសម្អាតគ្រឿងសង្ហារឹម (Furniture polish)
- សារធាតុធ្វើឱ្យអាកាសធាតុស្រស់ស្រាយ (Air fresheners)។

ខ. ថ្នាំកម្ចាត់សត្វចង្រៃក្នុងគេហដ្ឋានមានជាអាទិ៍៖

- ថ្នាំឬនុយកម្ចាត់កណ្ដុរ
- ថ្នាំកម្ចាត់សង្កើច
- ថ្នាំកម្ចាត់សត្វល្អិតរុក្ខជាតិក្នុងគេហដ្ឋាន
- ថ្នាំ និងសាប៊ូកម្ចាត់ចៃសត្វចិញ្ចឹម
- ថ្នាំឬនុយកម្ចាត់សត្វកន្លាត ស្រមោច ឬកណ្ដៀរ។

គ. សារធាតុប្រើប្រាស់សម្រាប់ការពារសួនក្នុងបរិវេណគេហដ្ឋានមានជាអាទិ៍៖

- ថ្នាំកម្ចាត់សត្វល្អិត (Insecticides)
- ថ្នាំកម្ចាត់ស្មៅ (Herbicides)
- ថ្នាំកម្ចាត់ផ្សិត (Fungicides)
- ថ្នាំការពារឈើ (Wood preservative)
- ស្អិត និងកាវ (Adhesive and Glues)
- ថ្នាំលាបគ្រឿងសង្ហារឹម (Furniture strippers)
- ថ្នាំប្រេង (Oil-or enamel-based paint)
- ថ្នាំបំបាត់ច្រេះ (Stains and finishes)
- សារធាតុរំលាយ (Chemical solvent)
- សារធាតុស្រូបសំណើម (Desiccant)។

ឃ. សារធាតុគីមីផ្សេងទៀតដែលមិនត្រូវបានអនុញ្ញាតប្រើប្រាស់ក្នុងម្ហូបអាហារ មានជាអាទិ៍៖

- បូរ៉ាក់ ( Borax )ឬ សូដ្យូមបូរ៉ាត ( Sodium Borate ) ឬ អាស៊ីដបូរិច ( Boric Acid)
- អាស៊ីដសាលីស៊ីលិច ( Salicylic Acid )
- ហ្វរម៉ាល់ដេអ៊ីដ ( Formaldehyde) ប៉ារ៉ាហ្វរម៉ាល់ដេអ៊ីដ ( Para Formaldehyde)
- ល័ក្តពណ៌ ( Synthetic Dyes) ដូចជា ប៉ារ៉ាក្រហម( Para Red) រ៉ូដាមីនបេ( Rhodamine B ) ស៊ូដានក្រហម( Sudan Red) ម៉ាឡាឆាយបៃតង ( Malachite Green )
- មេឡាមីន( Melamine )។

**ប្រការ៨.-**

បុគ្គលធ្វើធុរកិច្ចផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន ដែលប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្នើសុំលិខិតអនុញ្ញាតបន្ថែមពីក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដូចខាងក្រោម៖

- ចំពោះរូបវន្តបុគ្គលត្រូវស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីក្រសួងពាណិជ្ជកម្ម និងវិញ្ញាបនបត្រសេវាអនឡាញពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ចំពោះនីតិបុគ្គលត្រូវស្នើសុំអាជ្ញាបណ្ណឱ្យប្រតិបត្តិការផ្តល់សេវាកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីក្រសួងពាណិជ្ជកម្ម និងវិញ្ញាបនបត្រសេវាអនឡាញពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ៩.-**

ហាមផ្ទេរផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន (ប្រភពដើម) ពីប្រអប់វេចខ្ចប់មួយទៅប្រអប់វេចខ្ចប់មួយទៀត ឬពីធុងមួយទៅធុងមួយទៀត ក្នុងគោលបំណងចែកចាយដោយគ្មានការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ ផលិតផលថ្មីដែលទទួលបានពីការផ្ទេរត្រូវដាក់ស្លាកសញ្ញាឱ្យបានត្រឹមត្រូវ ដោយអនុលោមតាមបទដ្ឋានព័ត៌មានដូចបានកំណត់ក្នុងប្រការ៦នៃប្រកាសនេះ។

**ប្រការ១០.-**

បុគ្គលធ្វើធុរកិច្ចផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន ត្រូវមានឯកសារពាក់ព័ន្ធ ពីប្រភពដែលបានផ្គត់ផ្គង់ផលិតផល និងត្រូវផ្តល់នូវឯកសារទាំងនោះ តាមការតម្រូវរបស់មន្ត្រីមានសមត្ថកិច្ច ដើម្បីបង្កភាពងាយស្រួលដល់ការអង្កេតដាន និងការប្រមូលត្រឡប់មកវិញនូវផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន ដែលត្រូវបានរកឃើញ ឬទទួលបានព័ត៌មានថាគ្មានសុវត្ថិភាពដល់អ្នកប្រើប្រាស់ ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស។

**ប្រការ១១.-**

បុគ្គលធ្វើធុរកិច្ចផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន ដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការដាក់ស្លាកសញ្ញា និងលក្ខខណ្ឌនានា ដូចមានកំណត់ក្នុងប្រកាសនេះត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតជាធរមាន។

**ប្រការ១២.-**

ប្រកាសនេះត្រូវអនុវត្តភ្លាមបន្ទាប់ពីចុះហត្ថលេខា លើកលែងតែរាល់ផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន ដែលបាននឹងកំពុងចែកចាយលើទីផ្សារហើយ ដោយទុករយៈពេល៣(បី)ខែ ដើម្បីឱ្យធុរជនធ្វើការកែតម្រូវ។

**ប្រការ១៣.-**

សមាសភាពគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» អគ្គនាយក អគ្គាធិការ គ្រប់អង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ប្រតិបត្តិករអាជីវកម្មផលិតផលគីមីប្រើប្រាស់តាមគេហដ្ឋាន និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៧ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែកញ្ញា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ